NSW GOVERNMENT

STUDY AUSTRALIA

# សាលារបស់រដ្ឋ NSW

## កម្មវិធីសិស្ស អន្តរជាតិ

អនាគតរបស់អ្នកចាប់ផ្តើម ថ្ងៃនេះ





# កម្មវិធីសិស្ស អន្តរជាតិ

## អនាគតរបស់ អ្នកចាប់ផ្តើម ថ្ងៃនេះ

សាលារដ្ឋក្នុង New South Wales (NSW) គឺផ្តល់ឱកាសដែលមានភាពរីករាយក្នុងការរស់នៅ និងរៀនក្នុងសហគមន៍ដែលមានជាតិសាសន៍ ចម្រុះ រួសរាយ និងសុវត្ថិភាព។

ជាប្រព័ន្ធអប់រំធំជាងគេក្នុងប្រទេសអូស្ត្រាលី ប្រព័ន្ធក្នុងសាលារបស់យើង គឺត្រូវបានទទួលស្គាល់សម្រាប់ គុណភាពល្អឥតខ្ចោះ មុខវិជ្ជាសិក្សាដែលមានភាពច្នៃប្រឌិត និងសម្បូរបែប និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលច្នៃប្រឌិតនៅក្នុងថ្នាក់រៀន។

ការអប់រំរបស់សាលារដ្ឋមួយក្នុង NSW ផ្តល់កម្មវិធីសិក្សារហូតដល់ថ្នាក់ទី 12 និងជាការត្រៀមខ្លួនដ៏ល្អបំផុត សម្រាប់ការចូលរៀនក្នុងសកលវិទ្យាល័យក្នុងស្រុក និងអន្តរជាតិ។

កម្មវិធីវគ្គខ្លីដែលពេញនិយមរបស់ពួកយើងត្រូវបានបង្កើតឡើងដើម្បីផ្តល់រសជាតិនៃជីវិតក្នុងប្រទេសអូស្ត្រាលី ដោយផ្តល់ឱកាសក្នុងការសិក្សាជាច្រើន។

មានអ្វីដែលត្រូវធ្វើ និងមើលជាច្រើននៅក្នុង NSW ដោយរួមបញ្ចូលទាំងឆ្នេរសមុទ្រ សារមន្ទីរ និង កំពង់ផែដ៏ស្អាតបំផុតរបស់ពិភពលោក។

**សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័ររបស់យើង**

**deinternational.nsw.edu.au**

ពីសាលាបឋមសិក្សារហូតដល់វិទ្យាល័យ សាលារដ្ឋក្នុងទីក្រុង Sydney និងនៅក្នុងរដ្ឋ NSWW ផ្តល់ឧត្តមភាពនៃការសិក្សាជាមួយបរិយាកាសស្វាគមន៍ រួសរាយ និងសុវត្ថិភាព។

### ការសិក្សាផ្តោតលើអនាគត

បច្ចេកទេសនៃការបង្រៀនដែលមានភាពច្នៃប្រឌិតជួយអភិវឌ្ឍជំនាញ និងសមត្ថភាពសិស្សដើម្បីលូតលាស់ក្នុងពិភពលោក ដែលមានទំនាក់ទំនងគ្នា និងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ សិស្សអភិវឌ្ឍទំនុកចិត្តខ្លួនឯង និងជំនាញក្នុងការរៀនឯករាជ្យតាមរយៈ ការស្រាវជ្រាវ ការដោះស្រាយបញ្ហាក្នុងជីវិតប្រចាំថ្ងៃ ការធ្វើគម្រោងជាក្រុម និងឱកាសជាអ្នកដឹកនាំ។

### កម្មវិធីសិក្សា

សិស្សអន្តរជាតិដែលបញ្ចប់ពីសាលារដ្ឋក្នុង NSW គឺរៀបចំខ្លួនបានល្អ សម្រាប់ការសិក្សាបន្តនៅសកលវិទ្យាល័យក្នុងប្រទេសអូស្ត្រាលី ឬក្រៅប្រទេស។

### ការបង្រៀនមានលក្ខណៈពិសេស

គ្រូដែលបានបណ្តុះបណ្តាលនៅសកលវិទ្យាល័យ និងមានលក្ខណៈសម្បត្តិខ្ពស់របស់ពួកយើង គឺត្រូវបានគេទទួលស្គាល់ដោយឆ្លងកាត់អជ្ញាធរស្តង់ការការអប់រំ NSW (NESA)។ ការបង្ហាត់បង្រៀនដែលគួរអោយចាប់អារម្មណ៍ និងមានគុណភាពខ្ពស់បូករួមនឹងទំហំថ្នាក់តូច ជួយអោយសិស្សសម្រេចគោលដៅបានល្អបំផុត។

### ការគាំទ្ររបស់សាលា

សិស្សទទួលបានការថែទាំជាលក្ខណៈបុគ្គលជាមួយបរិយាកាសនៃការសិក្សាដែលមានទំនុកចិត្ត និងសុវត្ថិភាព។ រាល់សាលាទាំងអស់ផ្តល់កម្មវិធីតម្រង់ទិស និងកម្មវិធីធ្វើការជាគូររវាងសិស្សអន្តរជាតិ និងសិស្សក្នុងស្រុក។ សាលានីមួយៗមានក្រុមសកម្មដើម្បីផ្តល់ការគាំទ្រដែលបន្តទៅមុន។

### សម្ភារៈបរិក្ខារកំរិតពិភពលោក

សាលារបស់យើង គឺមានទីតាំងធំទូលាយជាមួយវិទ្យាសាស្ត្រទំនើប មន្ទីរពិសោធន៍ផ្នែកភាសា និងមនុស្សយន្ត បណ្ណាល័យ សាលប្រជុំ កន្លែងហាត់កីឡា និងសម្ភារៈបរិក្ខារកម្សាន្ត និងកីឡាជាច្រើន។

បច្ចេកវិទ្យាឌីជីថល គឺត្រូវបានរួមបញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលា និងមានភ្ជាប់ជាមួយ WiFi ការប្រជុំតាមវីឌីអូ និងឧបករណ៍ជាច្រើនទៀត។

### ការគាំទ្រលើភាសាអង់គ្លេសយ៉ាងល្អិតល្អន់

មជ្ឈមណ្ឌលភាសាអង់គ្លេសយ៉ាងល្អិតល្អន់របស់យើង (IECs) គឺអាចអោយសិស្សអភិវឌ្ឍជំនាញភាសាអង់គ្លេស ដូច្នេះពួកគេផ្លាស់ទៅវិទ្យាល័យជាមួយទំនុកចិត្ត។



# ការសិក្សាក្រៅប្រទេស

សម្រាប់សិស្សវិទ្យាល័យ កម្មវិធីសិក្សាក្រៅប្រទេសរយៈពេលខ្លីនៅសាលារដ្ឋក្នុង NSW គឺផ្តល់ឱកាស រីករាយដើម្បីទទួលបានបទពិសោធន៍ពីជីវិតរស់នៅដែលប្លែកគេក្នុងប្រទេសអូស្ត្រាលី ខណៈពេលដែលអ្នករៀន។

### ជម្រើសក្នុងការសិក្សា

សាលារដ្ឋក្នុង NSW គឺផ្តល់មុខវិជ្ជាជាច្រើនទៅអោយសិស្សដែលសិក្សាក្រៅប្រទេស រួមបញ្ចូល ការសម្តែង និងសិល្បៈបែបច្នៃប្រឌិត ភាសា បច្ចេកវិទ្យា និងមុខវិជ្ជារចនាជាមួយបច្ចេកវិទ្យាឈានមុខគេបំផុត និងធនធានសិក្សាតាមអ៊ីនធើណេតជាច្រើន។

សិស្សតម្រូវអោយចេះភាសាអង់គ្លេសគ្រប់គ្រាន់សម្រាប់ការចូលរៀនដោយផ្ទាល់។

សិស្សអាចទទួលបានការទុកចិត្តចំពោះការសិក្សាក្នុងប្រទេសអូស្ត្រាលី នៅពេលពួកគេបន្តការសិក្សាក្នុងប្រទេសកំណើតរបស់ពួកគេ។

### រយៈពេលនៃកម្មវិធីសិក្សា

1 វគ្គ = 3 ខែ

2 វគ្គ = 6 ខែ

3 វគ្គ = 9 ខែ

4 វគ្គ = 12 ខែ

### កំរិតថ្នាក់ក្នុងសាលា

ការសិក្សាក្រៅប្រទេស គឺសម្រាប់សិស្សថ្នាក់ទី 9,10 និង 11។

### ការស្នាក់នៅ

ផ្នែកសំខាន់នៃបទពិសោធន៍ក្នុងការសិក្សាក្រៅប្រទេស គឺការរស់នៅជាមួយគ្រួសារជនជាតិអូស្ត្រាលី។ ការរស់នៅក្នុងផ្ទះ ផ្តល់ឱកាសដ៏ពិសេសដើម្បីរៀនបន្ថែមពីជីវិតរស់នៅរបស់ជនជាតិអូស្ត្រាលី និងជួយបង្កើនជំនាញភាសាអង់គ្លេសផងដែរ។

### កីឡា

កីឡា គឺជាផ្នែកដ៏សំខាន់មួយនៃជីវិតរស់នៅរបស់ជនជាតិអូស្ត្រាលី និងសាលាភាគច្រើនផ្តល់កីឡាជាច្រើនប្រភេទរួមទាំងការរៀនជិះក្តារលើរលក។ កីឡាដែលមានក្នុងសាលានីមួយៗអាចខុសគ្នា។

ព័ត៌មាននៃសាលាច្រើនជាង 25 សម្រាប់កម្មវិធីសិក្សាក្រៅប្រទេសជាមួយនឹងប្រព័ន្ធផែនទី គឺអាចរកបាននៅលើគេហទំព័ររបស់យើង។



# ដំណើរទស្សនកិច្ចសិក្សា

ដំណើរទស្សនកិច្ចសិក្សាផ្តល់អោយមានការធ្វើដំណើរជាក្រុមជាមួយនឹងកម្មវិធីស្មើភាពគ្នានៃសកម្មភាពអប់រំទស្សនកិច្ចបែបវប្បធម៌ និងទំនាក់ទំនងជាមួយសិស្សជនជាតិអូស្ត្រាលី។

### ដំណើរទស្សនកិច្ចសិក្សារបស់សិស្ស

ដំណើរទស្សនកិច្ចសិក្សារបស់សិស្ស គឺសម្រាប់មួយក្រុមៗមានគ្នា 10 នាក់ ឬច្រើនជាងនេះ ដែលមានអាយុចាប់ពី 10 ឆ្នាំឡើងទៅ។ ដំណើរទស្សនកិច្ចអាចមានរយៈពេលពីកន្លះថ្ងៃ ទៅ ដប់សប្តាហ៍។

### ដំណើរទស្សនកិច្ចសិក្សាអាចរួមបញ្ចូល:

- ការរៀនជាមួយសិស្សជនជាតិអូស្ត្រាលីក្នុងថ្នាក់ទូទៅ
- ការបង្កើតមិត្តជាមួយសិស្សដែលជាដៃគូរជនជាតិអូស្ត្រាលី
- ដំណើរកម្សាន្តទៅកាន់ឆ្នេរសមុទ្រស្អាតៗ ឧទ្យានជាតិ ឧទ្យានសត្វព្រៃរបស់អូស្ត្រាលី និងទីកន្លែងល្បីៗនៅទីក្រុង Sydney។

### ដំណើរទស្សនកិច្ចពិសេសផ្តល់កម្មវិធីសិក្សាដូចជា:

- បរិស្ថាន/វិទ្យាសាស្ត្រ
- ភាពជាអ្នកដឹកនាំ/ការធ្វើការជាក្រុម
- ការសម្តែងសិល្បៈ
- កីឡា

### ដំណើរទស្សនកិច្ចសិក្សាមនុស្សពេញវ័យ

ដំណើរទស្សនកិច្ចសិក្សាមនុស្សពេញវ័យ គឺសម្រាប់នាយកសាលា គ្រូបង្រៀន និងមន្ត្រីរដ្ឋាភិបាល និងអាចរួមបញ្ចូល:

- ទស្សនកិច្ចសាលា
- សង្កេតមើលការបង្ហាញពីវិធីសាស្ត្រក្នុងការបង្រៀនផ្សេងៗចំពោះគោលការណ៍អប់រំ ការគ្រប់គ្រង កម្មវិធីសិក្សា និងការគាំទ្រគ្រូបង្រៀន។
- កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

### ជម្រើសតាមតម្រូវការ

ដំណើរទស្សនកិច្ចសិក្សាត្រូវបានបង្កើតឡើងដើម្បីស្របតាមតម្រូវការនៃក្រុមនីមួយៗ។

សូមចំណាំថាដំណើរទស្សនកិច្ចសិក្សាអាចត្រូវបានរៀបចំឡើងដោយអ្នករៀបចំទស្សនកិច្ចដែលបានចុះឈ្មោះជាមួយដំណើរទស្សនកិច្ចសិក្សាអន្តរជាតិ DE តែប៉ុណ្ណោះ។




**NSW Government Schools**
NSW Department of Education
PO Box R1468 Royal Exchange
NSW 1225 Australia

1300 300 229 (option 2) in Australia
deinternational.nsw.edu.au/contact-us (outside Australia)

isc@det.nsw.edu.au
deinternational.nsw.edu.au



CRICOS PROVIDER NAME: NSW DEPARTMENT OF EDUCATION
CRICOS PROVIDER CODE: 00588M


deinternational.nsw.edu.au